

ធនាគារ ប្រៃសណីយ៍កម្ពុជា
東埔寨郵政銀行 CAMBODIA POST BANK

# ព្រឹត្តិបត្រព័ត៌មាន

ខែតុលា ឆ្នាំ២០២៥ | លេខ០៩

## សេដ្ឋកិច្ច និងវិស័យធនាគារ នៅក្នុងប្រទេសកម្ពុជា



សេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមនឹងភាពមិនប្រាកដប្រជា ដែលបង្កឡើងដោយកត្តាខាងក្រៅ និងបញ្ហាប្រឈមថ្មីក្នុងវិស័យហិរញ្ញវត្ថុក្នុងស្រុក។ បញ្ហាចម្បង គឺជាភាពមិនប្រាកដប្រជានៃអត្រាពន្ធដ៏ខ្ពស់របស់សហរដ្ឋអាមេរិកមកលើកម្ពុជា និងរយៈពេលនៃការយកពន្ធដ៏ខ្ពស់នេះ។

- ផលិតផលក្នុងស្រុកសរុប (GDP) កម្ពុជា បានកើនឡើងនៅឆ្នាំ ២០២៤ (៦,០%) ប៉ុន្តែកំណើននៅពេលអនាគត ត្រូវបានគេរំពឹងថានឹងទាបជាងឆ្នាំ២០២៤ ដោយសារតែអត្រាពន្ធខ្ពស់ពីសហរដ្ឋអាមេរិក។ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានគេរំពឹងថានឹងធ្លាក់ចុះមកនៅត្រឹម ៤,៩% នៅឆ្នាំ ២០២៥ និង ៤,៧% នៅឆ្នាំ ២០២៦។
- អតិផរណាបានធ្លាក់ចុះ ប៉ុន្តែនៅតែមានភាពប្រែប្រួល។ នៅឆ្នាំ ២០២៤ អតិផរណានៃសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់ (CPI) ជាមធ្យមគឺ0,៨% ប៉ុន្តែមានការប្រែប្រួលយ៉ាងខ្លាំងក្នុងឆ្នាំ២០២៤ និងដើមឆ្នាំ២០២៥។ អតិផរណានេះ ត្រូវបានគេរំពឹងថានឹងកើនឡើងដល់២,៥% នៅឆ្នាំ២០២៥ បន្ទាប់មកនឹងថយមកត្រឹម២,៣% នៅឆ្នាំ២០២៦ ស្មើនឹងអត្រានៃអតិផរណាមុនពេលមានការរាតត្បាតនៃជំងឺកូវីដ។
- ជំហរខាងក្រៅរបស់កម្ពុជានៅតែមានភាពរឹងមាំគួរសម។ នៅឆ្នាំ២០២៤ ជញ្ជីងពាណិជ្ជកម្មកម្ពុជា មានអតិរេក0,៥%នៃ GDP បើធៀបនឹងឆ្នាំ២០២៣ បានធ្លាក់ចុះ ដោយសារឱនភាពពាណិជ្ជកម្មកាន់តែធំ។ លំហូរចូល FDI នៅតែរឹងមាំក្នុងកម្រិត ៩,២% នៃផលិតផលក្នុងស្រុកសរុប។ ទោះជាយ៉ាងណាក៏ដោយ ជញ្ជីងពាណិជ្ជកម្មរបស់កម្ពុជា ត្រូវបានគេរំពឹងថានឹងមានឱនភាព៣,៥% ក្នុងឆ្នាំ២០២៥ និង៥,៤% ក្នុងឆ្នាំ ២០២៦ ដោយសារឱនភាពពាណិជ្ជកម្មបន្តកើនឡើង។
- អត្រាប្តូរប្រាក់រៀលមានស្ថិរភាពល្អ។ ប្រាក់រៀលបានឡើងថ្លៃបន្តិចធៀបនឹងប្រាក់ដុល្លារអាមេរិកក្នុងឆ្នាំ ២០២៤ និងមានការប្រែប្រួលបន្តិចបន្តួចតាមតម្រូវការជាក់ស្តែងនៅលើទីផ្សារ។

- ទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជាបានកើនឡើងដល់ ២៤,៨ ពាន់លានដុល្លារគិតត្រឹមខែមេសា ឆ្នាំ ២០២៥ ស្មើនឹង ៨,៧ ខែនៃការនាំចូល។
- កំណើនឥណទាននៅតែមានកម្រិតទាប ខណៈគុណភាពទ្រព្យសកម្មក្នុងវិស័យធនាគារបន្តធ្លាក់ចុះ។ ការចុះខ្សោយនៃកំណើនឥណទាននេះ ចាប់ផ្តើមតាំងពីឆ្នាំ២០២៣។ អនុបាតឥណទានមិនដំណើរការ (NPL) សម្រាប់ធនាគារបានបន្តកើនឡើងដល់៧,៨% នៅចុងខែមីនា ឆ្នាំ២០២៥។ និន្នាការនេះអាចធ្វើឲ្យថយចុះប្រាក់ចំណេញ និងដើមទុនរបស់ធនាគារ។
- ធនាគារជាតិនៃកម្ពុជានៅតែរក្សាគោលនយោបាយសម្របសម្រួលរបស់ខ្លួន ដើម្បីជួយសេដ្ឋកិច្ចក្នុងអំឡុងពេលមានកំណើនយឺត។ ទន្ទឹមនឹងនេះ វិធានការបណ្តោះអាសន្ន ដែលអនុញ្ញាតឱ្យធនាគារមានពេលវេលាបន្ថែមក្នុងការដោះស្រាយបញ្ហាឥណទានមិនដំណើរការ គួរតែមានពេលវេលាកំណត់ច្បាស់លាស់ ដើម្បីជៀសវាងហានិភ័យចិត្តសាស្ត្រ ហើយអាជ្ញាធរគួរតែចាត់វិធានការយ៉ាងសកម្មដើម្បីកែលម្អការគ្រប់គ្រងឥណទានមិនដំណើរការ។
- អាកាសយានដ្ឋានអន្តរជាតិតេជោថ្មីរបស់កម្ពុជា បានចាប់ផ្តើមដំណើរការជាផ្លូវការនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥។ ការអភិវឌ្ឍន៍ដ៏គួរឱ្យកត់សម្គាល់នេះ ត្រូវបានគេរំពឹងថានឹងជួយជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើតការងារ ជំរុញអាជីវកម្មក្នុងស្រុក និងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។ អាកាសយានដ្ឋានថ្មីនេះ ក៏នឹងជួយសម្រួលដល់ពាណិជ្ជកម្ម ដោយជំរុញវិស័យផ្សេងៗក្រៅពីវិស័យទេសចរណ៍ផងដែរ។
- នៅខែសីហា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានប្រកាសអំពីវិធានការអនុញ្ញាតឱ្យធនាគាររៀបចំឥណទានឡើងវិញសម្រាប់អតិថិជនដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ ការអនុវត្តនេះ នឹងបន្តមានប្រសិទ្ធភាពរហូតដល់ចុងឆ្នាំ២០២៥ ដើម្បីផ្តល់ភាពបត់បែន និងពេលវេលាឱ្យអតិថិជនក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ដែលជួយកាត់បន្ថយផលប៉ះពាល់នៃឥណទានមិនដំណើរការ ទាំងសម្រាប់ធនាគារ និងអតិថិជន។
- ដើម្បីផ្តល់សន្ទនីយភាពចូលទៅក្នុងទីផ្សារ ធនាគារជាតិនៃកម្ពុជាបានរក្សាសមាមាត្រតម្រូវការបម្រុង (RRRs) សម្រាប់រូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេសនៅកម្រិត ៧% ហើយបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (BFIs) រក្សាទ្រនាប់ដើមទុនខនស៊ើរវេសិន (CCB) នៅត្រឹម ១,២៥% រហូតដល់ចុងឆ្នាំ២០២៥។
- ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាក៏បានទម្លាក់អត្រាយោង — ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) រយៈពេល ៧ ថ្ងៃ — ចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០២៤។ ដើម្បីបង្កើនភាពបត់បែនរបស់ធនាគារក្នុងការគ្រប់គ្រងសាច់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានទម្លាក់តម្រូវការរក្សាទ្រព្យសកម្មបម្រុងប្រចាំថ្ងៃសម្រាប់ប្រាក់រៀលមកត្រឹម ៣០% ក្នុងខែមករា ឆ្នាំ ២០២៥ និងបង្កើនការបែងចែក LPCO នៅក្នុងការដេញថ្លៃនីមួយៗ។

## Real GDP growth and sectoral contributions to real GDP growth




## International Reserve



ជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហតូច សេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមនឹងការកើនឡើងនៃភាពមិនប្រាកដប្រជា ដែលបណ្តាលមកពីកត្តាខាងក្រៅ បញ្ហាប្រឈមនៅក្នុងវិស័យហិរញ្ញវត្ថុក្នុងស្រុក និងបញ្ហារចនាសម្ព័ន្ធដែល នៅតែបន្តកើតមាន។ ការព្រួយបារម្ភនាពេលបច្ចុប្បន្ន គឺភាពមិនប្រាកដប្រជាអំពីរយៈពេល និងទំហំនៃពន្ធខ្ពស់របស់សហរដ្ឋអាមេរិកមកលើកម្ពុជា។ លើសពីនេះ ការវាយតម្លៃឡើងវិញដោយ EU អំពីសិទ្ធិទទួលបាន EBA របស់កម្ពុជា អាចរារាំងការនាំចេញ។ កំណើនសេដ្ឋកិច្ចយឺតក្នុងប្រទេសធំៗមានភាពយ៉ាប់យឺនទៅៗ ប្រសិនបើនយោបាយការពារផលិតផលក្នុងស្រុកកើនឡើង ដែលដាក់សម្ពាធកាន់តែខ្លាំងលើការវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា។

នៅក្នុងប្រទេសកម្ពុជា ការថយចុះនៃគុណភាពឥណទាន និងកំណើនឥណទាន អាចប៉ះពាល់ដល់ប្រាក់ចំណេញ និងដើមទុនរបស់ធនាគារ។ បញ្ហាហិរញ្ញវត្ថុរបស់អ្នកអភិវឌ្ឍន៍អចលនទ្រព្យក៏អាចបង្កើនហានិភ័យឥណទានផងដែរ ហើយប្រសិនបើមិនត្រូវបានដោះស្រាយទេ បញ្ហាទាំងនេះអាចរីករាលដាលដល់សេដ្ឋកិច្ចកាន់តែទូលំទូលាយ។

ក្នុងរយៈពេលវែង ហានិភ័យរបស់កម្ពុជា អាចរួមមាន

- ហានិភ័យសកល ដូចជាភាពតានតឹងភូមិសាស្ត្រនយោបាយ ការប្រែប្រួលអាកាសធាតុ និងការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិត
- និងហានិភ័យក្នុងតំបន់ ដូចជាការកែសម្របខ្លួនយឺតរបស់ប្រទេសកំពុងអភិវឌ្ឍន៍។

Short Term Risks (Up to 2 years)




Source: AMRO Annual Consultation Report Cambodia – 2025 dated Aug 2025

# AMRO Annual Consultation Report

## Cambodia – 2025

# ធនាគារ ប្រៃសណីយ៍កម្ពុជា (CPBank) បានចូលរួមឧបត្ថម្ភ Diamond Sponsors ដល់ វេទិកាធុរកិច្ច និងនវានុវត្តន៍ ឆ្នាំ២០២៥ ដែលរៀបចំដោយ សភាពាណិជ្ជកម្មកម្ពុជា (Cambodia Chamber of Commerce)




ធនាគារ ប្រៃសណីយ៍កម្ពុជា (CPBank) បានចូលរួមឧបត្ថម្ភ Diamond Sponsors ដល់វេទិកាធុរកិច្ច និងនវានុវត្តន៍ ឆ្នាំ២០២៥ ដែលរៀបចំដោយ សភាពាណិជ្ជកម្មកម្ពុជា (Cambodia Chamber of Commerce) នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។

វេទិកានេះ ប្រារព្ធឡើង ដើម្បីចែករំលែកបទពិសោធន៍ ចក្ខុវិស័យ និងទស្សនៈទាន ក្នុងការលើកកម្ពស់ ធុរកិច្ច និងអាជីវកម្ម ឱ្យប្រសើរឡើងតាមបរិបទបច្ចេកវិទ្យា និងនវានុវត្តន៍។









# ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និង ទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥




សៀមរាប៖ នាថ្ងៃសៅរ៍ ទី៥ ខែកក្កដា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥ ដែលប្រារព្ធឡើងនៅសណ្ឋាគារ សោមាទេវី អង្គរវីសត និងស្ប៉ា ខេត្តសៀមរាប ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ និងមានការចូលរួមពីគណៈគ្រប់គ្រងជាន់ខ្ពស់ នាយក នាយិកាសាខាទាំងអស់របស់ធនាគារ ប្រៃសណីយ៍កម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ។











# ធនាគារ ប្រៃសណីយ៍កម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូ ជាមួយក្រុមហ៊ុន W-King Cambodia

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូ ជាមួយក្រុមហ៊ុន W-King Cambodia ក្នុងគោលបំណងពង្រឹងទំនាក់ទំនងអាជីវកម្មរវាងស្ថាប័នទាំង២ ដោយអតិថិជនរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ទាំងអស់ នឹងទទួលបានការបញ្ចុះតម្លៃ ៣% រាល់ការជាវ W-King Speaker គ្រប់ម៉ូដែលពី ក្រុមហ៊ុន W-King Cambodia ដោយគ្រាន់តែទូទាត់ជាមួយ CPBank App ឬប័ណ្ណវីសារបស់ CPBank។





**ទីតាំងហាងទី១៖ W-KING Cambodia TTP**

- ទីតាំងនៅលើ google map : https://g.co/kgs/4tgQ2cp
- អាសយដ្ឋានលេខ: ទួលទំពូង ផ្ទះលេខ 266 ផ្លូវ 155 សង្កាត់ទួលទំពូង ខណ្ឌចំការមន ភ្នំពេញ (ទល់មុខ ថៃហ្គ័រ ស្ទ័ហ្គារ)
- លេខទូរសព្ទទទួលការកម្ម៉ង់ : 086 404 747 / 012 404 747 / 093 777 776

**ទីតាំងហាងទី២៖ W-KING Cambodia**

- ទីតាំងនៅលើ google map : https://g.co/kgs/Yzys9r8
- អាសយដ្ឋានលេខ: ផ្ទះលេខ A333 ផ្លូវ371 សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ភ្នំពេញ (ទល់មុខក្លោងទ្វារ ជីបម៉ុងលេខទី2)
- លេខទូរសព្ទទទួលការកម្ម៉ង់ : 093 777 776 / 078 620 006 /097 6666 911



## លោកអ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ប្រធានក្រុមប្រឹក្សាភិបាល ធនាគារ ប្រៃសណីយ៍កម្ពុជា បាន ចូលរួមឧបត្ថម្ភថវិកា ១.០០០.០០០ដុល្លារ (១លានដុល្លារ) ដល់កងទ័ពជួរមុខ ដែលកំពុងឈរជើង ការពារបូរណភាពទឹកដីកម្ពុជានៅបណ្ដោយព្រំដែនកម្ពុជា-ថៃ។

តបតាមការអំពាវនាវរបស់ **សម្តេចតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា, **លោកអ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ** ប្រធានក្រុមប្រឹក្សាភិបាល ធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួមឧបត្ថម្ភថវិកា **១.០០០.០០០ដុល្លារ (១លានដុល្លារ)** នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥ ដល់កងទ័ពជួរមុខ ដែលកំពុងឈរជើងការពារបូរណភាពទឹកដីកម្ពុជានៅបណ្ដោយព្រំដែនកម្ពុជា-ថៃ។




## ធនាគារ ប្រៃសណីយ៍កម្ពុជា បានឧបត្ថម្ភគ្រឿងឧបភោគបរិភោគ តាមរយៈ រដ្ឋបាលខណ្ឌបឹងកេងកង ជូនដល់វីរៈកងទ័ព និងជនភៀសសឹកនៅតាមបណ្ដាខេត្តនានា

នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា បានឧបត្ថម្ភគ្រឿងឧបភោគបរិភោគ តាមរយៈ រដ្ឋបាលខណ្ឌបឹងកេងកង ជូនដល់វីរៈកងទ័ព និងជនភៀសសឹកនៅតាមបណ្ដាខេត្តនានា។








# ស្មារតីខ្មែរតែមួយ ខ្មែរដើម្បីខ្មែរ

## មូលនិធិសម្រាប់ជាតិយើង ទ្រទ្រង់ជូនៈ

## “ កងទ័ពជួរមុខ និងបងប្អូនជនភៀសសឹក ”

### ធនាគារ ប្រៃសណីយ៍កម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណន បានប្រមូលថវិកាជួយ បងប្អូនជនភៀសសឹក

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណន បានយកថវិកា ដែលបានប្រមូលបានពី «មូលនិធិសម្រាប់ជាតិយើង FOUNDATION FOR OUR NATION» ទៅទិញ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ ថ្នាំសង្កូវ និងថវិកាសម្រាប់ចែកជូនបងប្អូនជនភៀសសឹកស្ថិតនៅទីតាំងវត្ត ពោធិ៍សិលារាម(ហៅវត្តគីឡូ៨) សង្កាត់ប៉ាហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

ធនាគារក៏បានរៀបចំកញ្ចប់សម្ភារៈកូនខ្ចី សម្រាប់ស្ត្រីដែលទើបសម្រាលកូន ព្រមទាំងនំចំណី និងទឹកដោះគោសម្រាប់កុមារនៅក្នុងជំរំផងដែរ។











ធនាគារ ប្រៃសណីយ៍កម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណន បានយកថវិកាដែលនៅសេសសល់ពី «មូលនិធិសម្រាប់ជាតិយើង FOUNDATION FOR OUR NATION» រៀបចំជាគ្រឿងឧបភោគ បរិភោគ និងថវិកាសម្រាប់ចែកជូនបងប្អូនជនភៀសសឹកនៅជំរំមួយទៀតស្រុកវ៉ារិន នៅខេត្តសៀមរាប កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៥។
















# ធនាគារ ប្រៃសណីយ៍កម្ពុជា សាខាស្រុកត្រាំកក់-ឃុំតាភេម បានផ្លាស់ប្តូរទីតាំងថ្មី

ធនាគារ ប្រៃសណីយ៍កម្ពុជា សាខាស្រុកត្រាំកក់-ឃុំតាភេម បានផ្លាស់ប្តូរទីតាំងថ្មី ដែលមានអាសយដ្ឋាន នៅផ្លូវជាតិលេខ ៣ ភូមិខ្លាគ្រហឹម ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ។ អគារទីតាំងថ្មីរបស់ សាខាក្រុមហ៊ុនក្នុងស្រុកធនាគារ ប្រៃសណីយ៍កម្ពុជា (ស្រុកត្រាំកក់-ឃុំតាភេម) ត្រូវបានសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥ ដោយមានការចូលរួមដោយ សមាជិកក្រុមប្រឹក្សាភិបាល ប្រធាននាយកប្រតិបត្តិ គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកសាខា។

សាខាក្រុមហ៊ុនក្នុងស្រុកធនាគារ ប្រៃសណីយ៍កម្ពុជា (ស្រុកត្រាំកក់-ឃុំតាភេម) ជាអគារស្តង់ដាធំទូលាយ ដែលត្រូវបានបំពាក់ដោយប្រព័ន្ធការពារសុវត្ថិភាព និងសម្ភារៈធនាគារទំនើបៗ។ បុគ្គលិកធនាគារ ក៏ប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌សម្រាប់បម្រើសេវាជូនអតិថិជនផងដែរ។











# ធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួម ក្នុងកម្មវិធី “វេទិកាជាតិគណនេយ្យ ២០២៥”

ធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួម ក្នុងកម្មវិធី “វេទិកាជាតិគណនេយ្យ ២០២៥ ក្រោមប្រធានបទ “សុខដុមនីយកម្មបទប្បញ្ញត្តិ៖ ការរាយការណ៍ព័ត៌មានចីរភាព និងរបាយការណ៍ហិរញ្ញវត្ថុឌីជីថល”ដែលរៀបចំដោយ និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម អគ្គបណ្ឌិត សភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធាន អ.ស.ហ. ដែលធ្វើឡើងក្នុង មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៥។












# ធនាគារ ប្រៃសណីយ៍កម្ពុជា ចូលរួមអបអរសាទរការបើកដំណើរការ អាកាសយានដ្ឋានអន្តរជាតិតេជោ







ថ្នាក់ដឹកនាំជាន់ខ្ពស់ របស់ ធនាគារ ប្រៃសណីយ៍កម្ពុជា ដឹកនាំដោយ **លោកអ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ** ប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ បានចូលរួមអបអរសាទរការបើកដំណើរការ **អាកាសយានដ្ឋានអន្តរជាតិតេជោ** និងទទួលស្វាគមន៍ការមកដល់នៃជើងហោះហើរទី១ នៅព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក៏បានរៀបចំស្តង់នៅក្នុងអាកាសយានដ្ឋាន ដើម្បីត្រៀមទទួលស្វាគមន៍ និងបើកគណនីជូនអ្នកដំណើរ ដែលមកដល់ប្រទេសកម្ពុជា និងសាធារណៈជនផងដែរ។

ការបើកដំណើរការអាកាសយានដ្ឋានអន្តរជាតិថ្មីនេះ គឺជាការបោះជំហានដ៏សំខាន់មួយសម្រាប់ទ្រទ្រង់វិស័យអាកាសចរណ៍ និងសេដ្ឋកិច្ចកម្ពុជា ព្រមទាំងបានចូលខ្លួនមកជំនួសតួនាទីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបច្ចុប្បន្ន ដើម្បីក្លាយជាមជ្ឈមណ្ឌលអាកាសចរណ៍ដ៏សំខាន់សម្រាប់កម្ពុជា។








# ធនាគារ ប្រៃសណីយ៍កម្ពុជា បានប្រារព្ធពិធីអបអរសាទរគម្រប់ខួប ១២ឆ្នាំ នៃការបង្កើតធនាគារ

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា បានប្រារព្ធពិធីអបអរសាទរគម្រប់ខួប ១២ឆ្នាំ នៃការបង្កើតធនាគារ (ឆ្នាំ២០១៣-២០២៥) នៅភោជនីយដ្ឋាន ដីហ្រ្គេនធីរេស កម្មវិធីនេះប្រារព្ធឡើង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ និងមានការចូលរួមពីគណៈគ្រប់គ្រងជាន់ខ្ពស់ នាយក នាយិកា និងបុគ្គលិកគ្រប់ជាន់ថ្នាក់ នៃធនាគារ ប្រៃសណីយ៍កម្ពុជា និងហ្វូណនមីក្រូហិរញ្ញវត្ថុ។

ក្នុងរយៈពេល១២ឆ្នាំ ធនាគារ ប្រៃសណីយ៍កម្ពុជា បានរីកចម្រើនយ៉ាងឆាប់រហ័ស និងបានក្លាយជាធនាគារធំមួយក្នុងចំណោមធនាគារទាំង១០ នៅកម្ពុជា។

ធនាគារ ប្រៃសណីយ៍កម្ពុជា ១២ឆ្នាំ នៃឧត្តមភាព ទំនុកចិត្ត និងរីកចម្រើនជាមួយគ្នា!










## ធនាគារ ប្រៃសណីយ៍កម្ពុជា ប្រារព្ធពិធីបុណ្យកាន់បិណ្ឌនៅវត្តឧប្បលជោត្តនារាម ហៅវត្តភ្នួន

នាថ្ងៃសៅរ៍ ៦ រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៥ លោក តូច ចៅចេក ប្រធាននាយកប្រតិបត្តិ នៃធនាគារ ប្រៃសណីយ៍កម្ពុជា រួមទាំងគណៈគ្រប់គ្រង លោកនាយក-នាយិកាសាខា បុគ្គលិកនៃស្នាក់ការកណ្តាល និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណន ភីអិលស៊ី ដែលជាបុត្រសម្ព័ន្ធរបស់ធនាគារ ប្រៃណីយ៍កម្ពុជា បានអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌ (បិណ្ឌ ៦) ស្ថិតនៅវត្តឧប្បលជោត្តនារាម ហៅវត្តភ្នួន ស្ថិតនៅភូមិស្លែង ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

សូមជូនពរញាតិមិត្តបងប្អូន ទទួលបានបុណ្យកុសលទាំងអស់គ្នា និងធ្វើដំណើរកម្សាន្តទីជិតទីឆ្ងាយប្រកបដោយ សុវត្ថិភាព និងសេចក្តីរីករាយ!







## ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកិច្ចប្រជុំនាយក-នាយិកាសាខានៅស្នាក់ការកណ្តាល ដើម្បីត្រួតពិនិត្យលទ្ធផលការងារ និងកំណត់ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកិច្ចប្រជុំនាយក-នាយិកាសាខានៅស្នាក់ការកណ្តាល ដើម្បីត្រួតពិនិត្យលទ្ធផលការងារ និងកំណត់ផែនការសកម្មភាពសម្រាប់ខែបន្ទាប់។ យើងរួមគ្នា ដើម្បីបន្តផ្តល់សេវាហិរញ្ញវត្ថុដ៏ល្អបំផុតជូនអតិថិជន និងបន្តជំរុញកំណើនប្រកបដោយនិរន្តរភាពសម្រាប់អតិថិជន និងសហគមន៍របស់យើង។









# ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី កិច្ចប្រជុំបូកសរុបលទ្ធផលការងារ ឆមាសទី១ និងលើកទិសដៅអនុវត្តសម្រាប់ឆមាសទី២ នៃឆ្នាំ២០២៥

នាថ្ងៃសៅរ៍ ទី៥ ខែកក្កដា ឆ្នាំ២០២៥ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១ និងលើកទិសដៅអនុវត្តសម្រាប់ឆមាសទី២ នៃឆ្នាំ២០២៥ នៅទីហានវប្បធម៌ប្រវត្តិសាស្ត្រអង្គរ នៃក្រុងសៀមរាប ខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក ឃូ ប៊ុនទ្រី ប្រធាននាយកប្រតិបត្តិ នៃគ្រឹះស្ថាន។ គណៈគ្រប់គ្រងជាន់ខ្ពស់ បានលើកឡើងនូវលទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈម ព្រមទាំងដំណោះស្រាយនានា ដើម្បីជាទិសដៅ និងត្រីវិស័យក្នុងការអនុវត្តន៍បន្ត។ ក្នុងវប្បធម៌នៃការចែករំលែក គ្រឹះស្ថានមានឱកាសចូលរួមជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ទទួលបាននូវការចែករំលែកទស្សនៈទានលើ សារៈសំខាន់នៃបច្ចេកវិទ្យា និង បញ្ញាសិប្បនិម្មិត (Digitalization & AI) ក្នុងវិស័យធនាគារ និង នីតិវិធីច្បាប់លើការដោះបំណុល។ អង្គពិធីត្រូវបានបិទបញ្ចប់វេលាម៉ោង៥ល្ងាចក្នុងថ្ងៃដដែលក្រោមបរិយាកាសស្និទ្ធស្នាលក្រៃលែង និងប្រកបដោយក្តីរំពឹងខ្ពស់នៃលទ្ធផលដែលនឹងសម្រេចបានក្នុងឆ្នាំ២០២៥នេះ។









ធនាគារ កាណាឌីយ៉ា
加 華 銀 行
CANADIA BANK

ធនាគារ ប្រៃសណីយ៍កម្ពុជា
柬埔寨郵政銀行 CAMBODIA POST BANK

# ប្រើប្រាស់ ប័ណ្ណ ATM CSS CARD

## របស់ ធនាគារ កាណាឌីយ៉ា និង ធនាគារ ប្រៃសណីយ៍កម្ពុជា ដកប្រាក់នៅគ្រប់ម៉ាស៊ីន ATM របស់ស្ថាប័នទាំងពីរ

**ឥតគិតថ្លៃសេវា**

